# របាយការណ៍

## សិក្ខាសាលាស្តីពី

## “ទាំងអស់គ្នាដើម្បីអាជីវកម្ម និងសិទ្ធិមនុស្ស”

### ២១ ឧសភា ២០១០ ភោជនីយដ្ឋាន បៃតង —— ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

**សេចក្តីផ្តើម**

នៅថ្ងៃទី ២១ ឧសភា ២០១០, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានរៀបចំសិក្ខាសាលាមួយដែលជាផ្នែកមួយនៃគំរោងអាជីវកម្មនិង សិទ្ធិមនុស្ស ។សិក្ខាសាលានេះគឺជាផ្នែកមួយនៃសិក្ខាសាលាបន្តបន្ទាប់គ្នា ស្តីពី “ទាំងអស់គ្នាដើម្បីអាជីវកម្ម និង សិទ្ធិមនុស្ស” មានគោលដៅទៅដល់អ្នកតំណាងនៃវិស័យឯកជននៅកម្ពុជា។ សិក្ខាសាលាដែលមានការចូលរួមដោយសមាជិកនៃសហគមន៍អាជីវកម្មកម្ពុជា ត្រូវបានបង្កើតឡើងដើម្បីបង្ហាញ អ្នកដែលមានការពាក់ព័ន្ធទៅនឹងអាជីវកម្ម និងសិទ្ធិមនុស្ស និង បង្កើនការយល់ដឹងរបស់ពួកគេនៃសិទ្ធិមនុស្ស តាមរយៈការធ្វើបទបង្ហាញពី CCHR និងវាគ្មិន។ តាមរយៈសិក្ខាសាលា ចំនួននៃករណីសិក្សាត្រូវបានគេបង្ហាញ និងការពិភាក្សាជាក្រុមដែលទាក់ទងនឹងវិធី ដែលសកម្មភាពអាជីវកម្មអាចមានផលប៉ះពាល់ដល់សិទ្ធិមនុស្ស។ សកម្មភាពទាំងនោះត្រូវបានគេអនុវត្តជាមួយនឹងគោលបំណងនៃការផ្តួចផ្តើមនៃដំណើរការនៃការ បង្ករអោយមានអត្ថន័យពេញលេញនៃសិទ្ធិមនុស្ស ដោយផ្អែកលើកិច្ចពិភាក្សារវាង អាជីវកម្មកម្ពុជា និង សង្គមស៊ីវិល។ លើសពីនេះទៀត សិក្ខាសាលានេះបានបង្ហាញឱកាសយ៉ាងសំខាន់ក្នុងការពិភាក្សាលើ សេចក្តីថ្លែងការណ៍ស្តីពីគោល ការណ៍គោរពសិទ្ធិមនុស្ស (SOP), ជាកិច្ចព្រមព្រៀងដែលមិនចងកាតព្វកិច្ច មាន ១០ គោលការណ៍សំខាន់ មានទិសដៅជំរុញអោយអាជីវកម្មប្រមូលផ្តុំជាមួយនឹងកាតព្វកិច្ចគោរពសិទ្ធិមនុស្សរបស់ពួកគេ។ វាគ្មិនក្នុងកម្មវិធី មានលោក អាត់ ធន់, ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា និង លោក ចាន់ សាវ៉េត មន្ត្រី សម្របសម្រួលកម្មវិធីសិទ្ធិមនុស្សនៃ សមាគមន៍សិទ្ធិមនុស្សកម្ពុជា និងការអភិវឌ្ឍន៍ ADHOC ។

របាយការណ៍ខាងក្រោម នឹងពន្យល់ពីខ្លឹមសារសំខាន់នៃសិក្ខាសាលានេះ និងសង្ខេបពីបទពិសោធន៍ និងការជជែកវែកញែកដែលបានលើឡើងក្នុងកិច្ចប្រជុំពិភាក្សាគ្នានេះ។ របាយការណ៍នេះ ធ្វើឡើងដើម្បីត្រួតពិនិត្យតាមដានពីសិក្ខាសាលា និងសង្ឃឹមថាអាចជួយជាគំនិតដល់អ្នកចូលរួម និងអាចអោយពួកគេគិតអំពីជំហានបន្តបន្ទាប់ថា គួរធ្វើយ៉ាងដូចម្តេច ទាក់ទងទៅនឹងសិទ្ធិមនុស្សក្នុងអាជីវកម្ម។

**សាវតារ:**

សិក្ខាសិលានេះជា សិក្ខាសាលាលើកទីប្រាំ តាមលំដាប់លំដោយនៃសិក្ខាសាលាអាជីវកម្ម និង សិទ្ធិមនុស្ស របស់ CCHR/OHCHR សំរាប់ក្រុមដែលពាក់ព័ន្ធក្នុងវិស័យឯកជននៅកម្ពុជា។ សិក្ខាសាលាលើកទីមួយ ធ្វើឡើងសំរាប់អង្គការក្រៅរដ្ឋាភិបាល និង តំណាងសង្គមស៊ីវិលក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៩ គឺទទួលបានជោគជ័យ និង នាំទៅរកការកើនឡើងនៃការចូលរួមដើម្បីស្ថាបនាលើអាជីវកម្ម និង សិទ្ធិមនុស្សរវាងស្ថាប័នក្រៅរដ្ឋាភិបាល។ សិក្ខាសាលាលើកទីពីរផ្តួចផ្តើមអោយមានការចាប់ផ្តើមដំណើរការ នាំអោយមានកិច្ចពិភាក្សារវាង អាជីវកម្មកម្ពុជា និង សង្គមស៊ីវិល ដែលជាគោលបំណងស្នូលនៃគំរោងនេះ។

សិក្ខាសាលាលើកទីបី ទីបួន ទីប្រាំ ជាសិក្ខាសាលាត៧គ្នា និង មានទិសដៅលើកកំពស់ ការយល់ដឹង សិទ្ធិមនុស្សតាមរយៈ សេចក្តីថ្លែងការណ៍នៃគោលការណ៍ ស្តីពីអាជីវកម្ម និង សិទ្ធិមនុស្ស (SOP)។

សិក្ខាសាលាមុននេះ បានបង្ហាញពីជំហានដំបូងក្នុងការបង្កើតអោយមាន បរិយាកាសនៃការសហការដែល មិនប្រឈមមុខដាក់គ្នា លើអាជីវកម្ម និង សិទ្ធិមនុស្សរវាងក្រុមដែលពាក់ព័ន្ធ ក្នុងវិស័យឯកជន នៅកម្ពុជា។ វាគ្មិន ដែលជាតំណាងមកពីសហជីពការងារ និង NGOs នៅសិក្ខាសាលាទាំងនេះ បានជួយបង្កើនការ យល់ដឹងក្នុង ចំណោមអ្នកតំណាងអាជីវកម្ម ក្នុងការចូលរួម ដែលអាជីវកម្មអាចមានការ ប៉ះពាល់ដល់សិទ្ធិមនុស្សក្នុងប្រតិបត្តិការ របស់ពួកគេ។ តាមរយៈការពិភាក្សានៅក្នុងសិក្ខាសាលា, សេចក្តីថ្លែងការណ៍នៃ គោលការណ៍ស្តីពី អាជីវកម្ម និង សិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានគេតាក់តែងឡើង (SOP)។

## <u>គោលបំណងរបស់សិក្ខាសាលា</u>

សង្ឃឹមថាសិក្ខាសាលានេះនិងអាចៈ

- លើកកំពស់ការយល់ដឹងអំពីអ្វីជាសិទ្ធិមនុស្ស និងអំពីវិធីដែលសិទ្ធិមនុស្សមានការពាក់ព័ន្ធទៅនឹងអាជីវកម្ម
- អនុញ្ញាតអោយអ្នកតំណាងនៃសហគមន៍អាជីវកម្មចែករំលែកគំនិតយោបល់ លើទំនួលខុសត្រូវសង្គម (CSR) និងការគោរពសិទ្ធិមនុស្ស។
- ផ្តល់ឱកាសដើម្បីបង្កើតទំនាក់ទំនង រវាងវិស័យឯកជន និងសង្គមស៊ីវិល
- ពិភាក្សាបង្កើត សេចក្តីថ្លែងការណ៍ស្តីពីគោលការណ៍គោរពសិទ្ធិ លើគំរោងអាជីវកម្ម និង សិទ្ធិមនុស្សនៅ ព្រះរាជាណាចក្រកម្ពុជា។

## <u>*សិក្ខាសាលានេះត្រូវបានបែងចែកជា ៣ផ្នែកៈ*</u>

### ផ្នែក១ — កិច្ចស្វាគមន៍ និង សេចក្តីផ្តើម

លោក គង់ សំអុន, នាយកកម្មវិធី CCHR បានឡើងបើកសិក្ខាសាលា ជាមួយនឹងការបង្ហាញខ្លីៗពី ប្រធានបទនៃអាជីវកម្ម និង សិទ្ធិមនុស្ស។ គាត់បានសង្កត់ធ្ងន់ថាអាជីវកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុង វិស័យ

អាជីវកម្ម និងសិទ្ធិមនុស្ស។ វាអាស្រ័យលើអាជីវកម្មថាតើជាអ្នកការពារ ឬអ្នករំលោភសិទ្ធិមនុស្ស។ គាត់បានពន្យល់ថា អាជីវកម្មអាចប្តេជ្ញាខ្លួនឯង មិនធ្វើការរំលោភសិទ្ធិមនុស្ស ក្នុងប្រតិបត្តិការរបស់ពួកគេ។ ពួកគេអាចយល់ឃើញថាខ្លួនឯងជាអាជីវកម្មល្អដែលមានគោលការណ៍ និង ច្បាប់ផ្ទៃក្នុង ដែលអនុលោមតាមច្បាប់ សិទ្ធិមនុស្ស នានាជាជាងការរំលោភសិទ្ធិមនុស្ស។ គាត់បានបង្ហាញជាទូទៅថា អ្នករាល់គ្នារួមទាំងអាជីវកម្ម ត្រូវតែគោរពសិទ្ធិមនុស្ស និងសំរួលដល់ការប៉ះប៉ូវសង នៅពេលកើតមានការរំលោភសិទ្ធិមនុស្ស។ លោក គង់ សំអុន បានសរុបថា នៅកន្លែងដែលការការពារសិទ្ធិមនុស្សមានការព្រួយបារម្ភ រដ្ឋាភិបាលដែលទទួលខុសត្រូវសំរាប់ការ ការពារនៃសិទ្ធិមនុស្ស បន្តែ អាជីវកម្មមានទំនួលខុសត្រូវក្នុងការធានាថាសិទ្ធិត្រូវបានគេការពារ និងគោរព។

**ផ្នែក២ — ការពិភាក្សាលើអាជីវកម្មមានការគោរពសិទ្ធិមនុស្សនៅកម្ពុជា**

តាមរយៈសិក្ខាសាលាត១គ្នា វាគ្មិនផ្សេងៗគ្នាត្រូវបានគេអញ្ជើញមកចែករំលែកបទពិសោធន៍ជាមួយនឹងអ្នកចូលរួមផ្សេងៗ ជាមួយនឹងការធ្វើបទបង្ហាញ ២០នាទី។ ដំណើរការនេះអាចអោយអាជីវកម្មដំទៃរៀនពីបទពិសោធន៍ និង ឥរិយាបទនៃសហគ្រាសរីកចំរើនក្នុងសង្គម។

សិក្ខាសាលានេះមានការចូលរួមដោយ វាគ្មិនចំនួនពីររូបៈ

លោកអាត់ ធន់ និយាយពីតួនាទីសហជីពនៅក្នុងវិស័យអាជីវកម្មៈ

លោកអាត់ ធន់ធ្វើការផ្នែកសហជីពអស់រយៈពេល ១០ឆ្នាំហើយ។គោលបំណងសហជីពគឺ ធ្វើការតស៊ូមតិដោយគ្មានហឹង្សាដើម្បីសិទ្ធិកម្មករដើម្បីធានាថា ពួកគេមានជីវភាពរស់នៅសមរម្យ។ នៅក្នុងសង្គម មានមនុស្សមួយចំនួនមានទស្សនៈខុសអំពីសហជីពថា ពួកគេជាអ្នកបង្កបញ្ហា។ លោកអាត់ ធត់បង្ហាញថា ជាទូទៅ សហជីពមិនមានឈ្មោះល្អចំពោះការធ្វើការងារល្អ និង ជារឿយៗរារាំងដោយភាពចំរូងចំរាស់ ប៉ុន្តែ នៅសហរដ្ឋអាមេរិច និងប្រទេសនៅអឺរ៉ុបមួយចំនួន សហជីពដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយ ប្រជាជនអោយមានជីវភាពល្អប្រសើរ និងជួយរដ្ឋាភិបាលតំរង់ទិស និង គិតដល់ការចរចាររួម។

### ១ ‿សិទ្ធិបកម្មករ‿និយោជិត

**ក‿សិទ្ធិបង្កើតសហជីព** (Union Rights)

**- រដ្ឋធម្មនុញ្ញមាត្រា ៣៦**

កថាខណ្ឌទី៥ៈ ប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិបង្កើតសហជីព និងចូលរួមជាសមាជិក ។

កថាខណ្ឌទី៦ៈ ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់ ។

**-អនុសញ្ញា ពលកម្មអន្តរជាតិ** ឡើលេខ៨៧ ប្រទេសកម្ពុជាផ្តល់សច្ចាប័ន នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩ : បានធានាចំពោះសិទ្ធិកម្មករ-និយោជិត ទាំងអស់ក្នុងការបង្កើត និងចូលរួមជាមួយសហជីពឬសមាគមដោយ មិនចាំបាច់ សុំការអនុញ្ញាតជាមុនឡើយ ។

**-សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស**

**មាត្រា ២៣ៈ** មនុស្សគ្រប់រូមមានសិទ្ធិង្កើតសហជីព និងចូលរួមសហជីពដើម្បីការពារផលប្រយោជន៍ របស់ខ្លួន។

**-ច្បាប់ស្តីពីការងារមាត្រា ២៦៦ :** ដោយគ្មានការប្រកាន់អ្វីទាំងអស់ និងពុំចាំបាច់មានការអនុញ្ញាតជាមុនកម្មករនិយោជិត និងនិយោជកមានសិទ្ធិអង្គការវិជ្ជាជីវៈតាមការជ្រើសរើសរបស់ខ្លួន ក្នុងគោលបំណងសម្រាប់តែការសិក្សា លើកតម្កើងផលប្រយោជន៍ និងការពារសិទ្ធិក៏ដូចជាផលប្រយោជន៍ផ្នែកស្មារតី និងសំភារៈជាសមូហភាព និងជាឯកត្តជនចំពោះបុគ្គលដែលលក្ខន្តិកៈរបស់អង្គការនោះបានកំណត់ ។ រាល់អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតមានឈ្មោះថា " សហជីពកម្មករនិយោជិត" ។

## ខ-តើសហជីពធ្វើការយ៉ាងដូចម្តេច ? What dose Union do?

- សហជីពចរចាជាមួយនិយោជក ដើម្បីតំឡើងប្រាក់ឈ្នួល កែប្រែល័ក្ខខ័ណ្ឌការងារ ជីវភាពរស់នៅដល់សមជិកនិងក្រុម គ្រួសាររបស់ពួកគេទៅតាមលទ្ធភាព ។
- ដោះស្រាយបញ្ហាឱ្យសមាជិក ស្តាប់សមាជិកនូវរាល់សេចក្តីត្រូវការរបស់ពួកគេ ។
- រៀបចំកម្មវិធីប្រជុំ ប្រចាំសប្តាហ៍ និងប្រជុំប្រចាំខែ ( បង្រៀនពីច្បាប់ការងារ សិទ្ធិការងារ និងការចូលរួមក្នុងសហជីព)
- ចរចាធ្វើអនុសញ្ញារួមដើម្បីឱ្យបានប្រសើរជាងច្បាប់
- ស្រាវជ្រាវអំពីស្ថានភាពការងារ និងសេដ្ឋកិច្ចសង្គម
- គ្រប់គ្រងសមាជិក ហិរញ្ញវត្ថុ និងឯកសារផ្សេងៗ
- ធ្វើទំនាក់ទំនងជាមួយសហជីពជាតិ សហជីពអន្តរជាតិ និងអង្គការពាក់ព័ន្ធ នានា
- ធ្វើផែនការសកម្ម និងបង្កើតយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍន៍សហជីពរបស់ខ្លួន

## គ-ផលប្រយោជន៍សហជីពនៅក្នុងអាជីវកម្ម

### ១-ផលប្រយោជន៍សម្រាប់កម្មករ

- បានទទួលការបណ្តុះបណ្តាល ចំណេះដឹងថ្មី ច្បាប់ការងារ និងស្ថានភាពការងារសេដ្ឋកិច្ច ។

-ទទួលបានការពារពីក្រុមនិងមានឱកាសប្រាប់ឬស្នើនូវទុក្ខកង្វល់ឬសំណូមពរផ្សេងៗទៅនិយោជិតដោយសន្តិភាព ។

- បង្កើនការយល់ដឹងអំពីផលវិបាកឬក៏តម្រូវការរបស់និយោជិត និងបង្កើនការយល់ចិត្តគ្នានៅ កន្លែងការងារ ។

### ២-ផលប្រយោជន៍សម្រាប់និយោជិត

- មានអ្នកជួយផ្តល់យោបល់ ឬការស្នើឡើង នូវចំណុចខ្វះខាតដើម្បីបំពេញបង្គ្រប់
- មានអ្នកតំណាងពិតប្រាកដ ក្នុងការនាំពាក្យពីថៅកែទៅកម្មករនិយោជិត និងពីបុគ្គលិកទៅថៅកែវិញ ។
- សហជីពជួយសម្របសម្រួល និងពន្យល់ទៅកម្មករនៅផលវិបាកដែលជួបប្រទេះ ហើយសហការទៅវិញទៅមក

-សហជីពជួយពន្យល់ដល់កម្មករឱ្យសហការល្អបង្កើនជំនាញ និងបង្កើនការផលិត ធ្វើសេវាឱ្យមាន បរិមាណ និងគុណភាពល្អ និង ទាន់ពេល ។

## . ២ -ការធ្វើអាជីវកម្ម

ជាទូទៅគ្រប់អ្នកធ្វើអាជីវកម្មទាំងអស់មិនថាខ្នាតធំ ឬខ្នាតតូចនិងមធ្យមក៏ដោយគឺរិះរកមធ្យោបាយយ៉ាងណា ឱ្យទទួលបានភាពជោគជ័យ ពោលគឺការចំណេញគេជម្រុញឱ្យមាន ។

- ជាធម្មតាម្ចាស់អាជីវកម្មគេតែងតែចង់បានការផលិតផលបានច្រើន គុណភាពល្អ រយៈពេលខ្លី សេវាកម្មល្អ

**ក ‸ការធ្វើអាជីវកម្មប្រកបដោយបរាជ័យ**

-គេធ្វើផ្នែកទីផ្សារឱ្យមានការប្រកួតប្រជែង ដើម្បីដណ្តើមយកទីផ្សារ ពេលខ្លះគេមិនបានគិតអំពីល័ក្ខខ័ណ្ឌការងាររបស់កម្មករ និយោជិត។

-គេបង្ខំឱ្យធ្វើការច្រើនម៉ោងគ្មានពេលសម្រាក់

-គ្មានការជំរុញលើកទឹកចិត្ត ដូចជាផ្តល់ឱកាស ឱ្យប្រាក់ឈ្នួលឡើយ

-មិនបានគិតគូ និងរៀបចំប្រព័ន្ធបរិស្ថាននៅកន្លែងការងារ ធូលីកំដៅ ពន្លឺ សំលេង និងប្រព័ន្ធសុវត្ថិភាពនៅកន្លែងការងារផ្សេងៗទៀត

-គេមិនបានផ្តល់ឱកាសឱ្យមានការបង្កើតសហជីព ដើម្បីឱ្យបុគ្គលិកមានឱកាសសំដែងនូវសំណូមពរទុក្ខកង្វល់ និង បញ្ហាប្រឈមផ្សេងទៀតឡើយ (រំលោភច្បាប់) ។

**‸ ផលប៉ះពាល់ នៃការធ្វើបែបនេះ**

- បុគ្គលគ្មានការអំណត់ធ្វើការជាមួយ ដើម្បីបញ្ចេញសមត្ថភាពពិតដល់ការផលិត
- គ្មានជំនឿដល់ថៅកែ ខ្លួនមានសុវត្ថិភាពការងារ
- បង្កើននៅជម្ងឺប្រចាំកាយ គ្រោះថ្នាក់ជារឿយៗ មានផលវិបាកដល់ (ខ្លួនគេផ្ទាល់ ដល់រដ្ឋ និងដល់ក្រុមហ៊ុន )
- បាត់បង់នូវកំលាំងការងារជំនាញ អាចក្លាយទៅជាវិបត្តិការងារ ។

**‸ លទ្ធផលចុងក្រោយ**

- បុគ្គលិកបាត់បង់សមត្ថភាព មានជម្ងឺ និងចាក់ចេញពីក្រុមហ៊ុន

-កម្មករជំនាញគេរត់ទៅរកក្រុមហ៊ុនដទៃទៀត

-មានជម្លោះ រវាងកម្មករនិយោជកអាចឈានទៅរកកូដកម្ម បាតុកម្ម និងរឿងផ្ទៃក្នុងរបស់ក្រុមហ៊ុន ត្រូវបានលាតត្រដាងឱ្យគេដឹងទាំងអស់ ។

-បង្កើនឱ្យមានការពឹងពាក់ អ្នកមានអំណាចផ្សេង បង្កើតឱ្យមានអំពើពុករលួយ

-បាត់បង់កម្មករ និងស្ទះការផលិត

-បាត់បង់មុខមាត់ និងឱកាស ការប្រកួតប្រជែង

-មានការរំលោភសិទ្ធិ កម្មករធ្ងន់ធ្ងរ<br>
-ច្បាប់ការងារ<br>
-អនុសញ្ញាអន្តរជាតិ<br>
-រដ្ឋធម្មនុញ្ញ

} រំលោភសិទ្ធិមនុស្ស

**ខ ‸ការធ្វើអាជីវកម្មប្រកបដោយជោគជ័យ**

-ប៉ុន្តែបើចង់ឱ្យអាជីវកម្មប្រកបដោយជោគជ័យ និងមាននិរន្តភាពនោះ គ្មានតែប្តូរពីបរាជ័យមកវិញ នឹងមានហើយ

-បង្កើនការសហការជាមួយសហជីពជាដៃគូ

-បង្កើនការទទួលខុសត្រូវសង្គម

-បង្កើនជំនាញ និងបច្ចេកទេសក្នុងការធ្វើអាជីវកម្មដោយជោគជ័យ

-គោរពសិទ្ធិ កម្មករ (កម្មករជាមនុស្ស) គោរពសិទ្ធិមនុស្ស

លោក ចាន់ សាវ៉េតបានធ្វើបទបង្ហាញពី ស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជាៈ

លោកសាវ៉េត ចាប់ផ្តើមដោយការក្រលេកមើលទៅប្រវត្តិសាស្ត្រកម្ពុជា ដើម្បីជាគំនិតក្នុងការពិភាក្សា។ ចំនុចទីមួយរបស់គឺអំពីការអភិវឌ្ឍន៍ដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងប៉ារីស។ នេះជាកិច្ចព្រមព្រៀងដែលនាំកម្ពុជាទៅរកប្រជាធិបតេយ្យ។ ដើម្បីអនុវត្តប្រជាធិបតេយ្យនៅក្នុងប្រទេស វាត្រូវតែមានទីផ្សារសេរី ដែលមានក្រុមហ៊ុនសហគ្រាសចំរុះជាច្រើន។ ចំនុចទីពីរ សួរថាតើកិច្ចព្រមព្រៀងបាននាំអ្វីមក។ លោកសាវ៉េតបានបង្ហាញថាអ្នកចូលរួមទាំងអស់ត្រូវតែគិតដល់កាលៈទេសៈនេះ។ ក្នុងនាមគាត់ជាអ្នកធ្វើការផ្នែកសិទ្ធិមនុស្ស គាត់កត់សំគាល់ឃើញ ៤ វិស័យៈ វិស័យកាត់ដេរ សំណង់ ដីសម្បទានសេដ្ឋកិច្ច និង វិស័យកសិកម្ម។ យោងទៅតាមការ ស្រាវជ្រាវរបស់គាត់ ៤ វិស័យនេះមានការពាក់ព័ន្ធជាមួយនឹងអាជីវកម្ម។ លោកសាវ៉េត បន្តទៀតថាតើការពាក់ព័ន្ធរបស់អាជីវកម្មសំខាន់យ៉ាងណា។ ចំងល់នេះទាក់ទងនឹងអាជីវកម្មថ្នាក់ជាតិ និង អន្តរជាតិ។ ដូច្នេះ អនុសញ្ញាអន្តរជាតិ និងច្បាប់ក្នុងស្រុកមិនអាចគ្រប់ដណ្តប់លើអាជីវកម្មបានទាំងអស់ទេ។ គាត់និយាយថា ការដំណើរការអាជីវកម្មដោយគ្មានប្រាក់ចំណេញគឺមិនមែនជាការធ្វើអាជីវកម្មទេ។ ការរកចំនូលមិនដែលគិតដល់ការគោរពច្បាប់ទេ វាផ្តោតសំខាន់តែលើអត្ថប្រយោជន៍។ លោក សាវ៉េត ជឿថាប្រសិនបើយុទ្ធវិធីនៃអាជីវកម្ម គឺថាពួកគេអាចទាញប្រយោជន៍ ពួកគេនឹងធ្វើដោយមិនគិតពីផលប៉ះពាល់នៃបរិស្ថាន។ ប្រសិនបើវាជាករណី អាជីវកម្មត្រូវតែចំណាយប្រាក់ចំណេញរបស់ពួកគេខ្លះដើម្បីផ្តល់ជាសំណងដល់ការប៉ះពាល់។ លោក សាវ៉េត បានមើលឃើញនូវភាពអយុត្តិធមិកើតឡើងនៅក្នុងសង្គមកម្ពុជា។ គាត់បានលើកឡើងថាតើ រដ្ឋាភិបាលអាចជួយបានយ៉ាងម៉េច។

លោក សាវ៉េត បានលើកឧទាហរណ៍ពីការរំលោភសិទ្ធិមនុស្ស និង សិទ្ធិការងារៈ

- ការខ្វះខាតបទដ្ឋានសុវត្ថិភាព និង សុខភាព និង ការផ្តល់ឧបករណ៍ការពារផ្សេងៗ
- ការមិនទទួលបាន ឬទទួលបានមានកំរិត ក្នុងការព្យាបាល សេវាសង្គ្រោះបន្ទាន់ និង ការប៉ះប៉ូវសង នៅពេលកម្មករទទួលរងរបួស ឬ បាត់បង់ជីវិតនៅកន្លែងការងារ
- ទទួលបានប្រាក់ឈ្នួលទាបជាងប្រាក់អប្បរមា
- ពលកម្មកុមារ
- ម៉ោងការងារយូរ គ្មានការឈប់សំរាប់ពេលមានជំងឺ ឬឈប់ប្រចាំឆ្នាំ
- ខ្វះសុវត្ថិភាពការងារ អត់ធ្វើការ អត់ប្រាក់ឈ្នួល
- គ្មានសិទ្ធិចូលរួម ឬបង្កើតសហជីព
- ការបណ្តេញចេញដោយបង្ខំដោយសារដីសម្បទានសេដ្ឋកិច្ច

ជាចុងក្រោយ លោកសារ៉េតបានសង្កត់ធ្ងន់ថា ការចាប់អារម្មណ៍ជាមួយនឹងអាជីវកម្ម ទៅនឹងអ្វីដែលផលប៉ះពាល់ដល់បរិស្ថាន និង សិទ្ធិជាមូលដ្ឋានរបស់មនុស្ស។ គាត់បង្ហាញថា នៅពេលប្រជាជនបាត់បង់សិទ្ធិទាំងអស់ខ្លួន ពួកគេទាំងនោះនឹងក្លាយជាទាសករ បន្ទាប់មកប្រទេសជាតិមិនមានការអភិវឌ្ឍន៍តាមបទដ្ឋាន និង ប្រទេសជាតិនៅតែក្រីក្រ។

**ផ្នែកទី៣---ការពិភាក្សាលើសេចក្តីថ្លែងការណ៍ស្តីពីគោលការណ៍គោរពសិទ្ធិនៃគំរោងអាជីវកម្ម និង សិទ្ធិមនុស្ស:**

លោកគង់ សំអុនចាប់ផ្តើមដោយពន្យល់ថា SOP គឺផ្អែកលើគោលការណ៍សិទ្ធិមនុស្សដែលមានចែងក្នុងច្បាប់ជាតិ និង អន្តរជាតិ គឺមិនមែនជាចំណង និង មិនជាកាតព្វបង្ខំលើក្រុមហ៊ុនដែលចុះហត្ថលេខាទេ។ SOP ដូចជាឯកសារសំអាងមួយចំពោះក្រុមហ៊ុនដែលត្រូវបានគេអំពាវនាវ ដើម្បីធានាថាក្រុមហ៊ុនប្រកាន់ភ្ជាប់ទៅនឹងសិទ្ធិមនុស្ស។ ជាងនេះទៅទៀត SOP អាចត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនដើម្បីបង្ហាញពីការប្តេជ្ញាក្នុងការការពារ និង គោរពសិទ្ធិមនុស្ស ដែលជួយអោយពួកគេកសាងទំនាក់ទំនងល្អជាមួយនឹងបុគ្គលិករបស់ពួកគេ។

ការពិភាក្សានេះប្រព្រឹត្តទៅបានយ៉ាងល្អ។ ដោយមានការផ្តល់ជាយោបល់ដោយភាគីអ្នកចូលរួម ពាក្យពេចន៍ដែលប្រើប្រាស់ក្នុង SOP មានការផ្លាស់ប្តូរដែលកាន់តែងាយស្រួលយល់ និង កាន់តែមានអត្ថន័យ។ មានសំនួរជាច្រើនត្រូវបានគេសួរដើម្បីបង្ហាញបញ្ជាក់នូវចំនុចមួយចំនួននៅក្នុងគោលការណ៍ SOP។ ចុងបញ្ចប់នៃការពិភាក្សា អ្នកចូលរួមទាំងអស់មានការយល់ព្រមជាមួយនឹង SOP នេះ។ ពួកគេទាំងអស់បង្ហាញពីគោលបំណងក្នុងការចុះហត្ថលេខាលើ SOP នៅសិក្ខាសាលាដ៏ធំខាងមុខ។

**ផ្នែកទី ៤---បិទកម្មវិធី**

លោកគង់ សំអុនឡើងបិទសិក្ខាសាលា ដោយអរគុណចំពោះអ្នកចូលរួមចំពោះការ ចំណាយពេលក្នុងការចូលរួមនៅក្នុងសិក្ខាសាលា។ គាត់បង្ហាញថា ការពិភាក្សានៃ SOP ដំណើរការល្អដោយសារមានការចូលរួមរបស់ពួកគេ។ គាត់សង្ឃឹមថា សិក្ខាសាលា និង លទ្ធផលនៃការពិភាក្សា នឹងមានប្រយោជន៍សំរាប់អ្នកជំនាន់ក្រោយ។ លោកគង់ សំអុនបានបិទកម្មវិធីដោយរំលឹកអ្នកចូលរួមថា សិក្ខាសាលាដ៏ធំរបស់គំរោងនេះ នឹងធ្វើឡើងនៅថ្ងៃទី ១១ មិថុនា នៅសណ្ឋាគារ កាំបូឌីយ៉ាណា និង ផ្តោតសំខាន់លើ SOP។

***សង្ខេប:***

អ្វីដែលសិក្ខាសាលានេះសំរេចបានមាន:

- ការយល់នៃអ្វីដែលជាសិទ្ធិមនុស្ស និង វិធីដែលពួកគេមានការពាក់ព័ន្ធនឹងអាជីវកម្ម
- វិស័យឯកជន សហជីព និង បណ្តាញ NGOs គឺត្រូវបានគេបង្កើតឡើង និង កាន់តែមានច្រើនជាសមាជិកពីវិស័យនិមួយៗអោយកាន់តែស្គាល់គ្នា។
- SOP ត្រូវបានគេបង្កើតឡើង។

**<u>បើក និង បិទកម្មវិធីដោយៈ</u>**

លោក គង់ សំអុន——នាយកកម្មវិធី CCHR

**<u>វាគ្មិន និងអ្នករៀបចំៈ</u>**

លោក អាត់ ធន់--ប្រធាន CLC-CCAWDU

លោក ចាន់ សាវ៉េត——អ្នកសម្របសម្រួលកម្មវិធីសិទ្ធិមនុស្ស, ADHOC

លោក ចក់ សុភី——អ្នកសម្របសម្រួលគំរោង CCHR

កញ្ញា ឃុន កែវមុនី — មន្ត្រីគំរោង CCHR

Bijan Hoshi — អ្នកហាត់ការ CCHR

លោក លាង ផាន់ណារ៉ា — អ្នកហាត់ការ CCHR